# សិលាចារឹកប្រាសាទក្ដុំសណ្ដក K.១៩២

## ១- ព័ត៌មានទូទៅ

ប្រាសាទក្ដុំសណ្ដកស្ថិតនៅភូមិតែល ឃុំស្រយ៉ង់ ស្រុកគូលែន ខេត្តព្រះវិហារ។ តាមរយៈគេហទំព័រ CISARK[១] បានឱ្យដឹងថាប្រាសាទនេះមានកំពែងពីរជាន់ ដែលសង់ឡើងពីថ្មបាយក្រៀម និងជណ្ដើរថ្មបាយក្រៀមនៅជម្រាលភ្នំខាងត្បូង។ កំពែងជាន់ទីមួយមានច្រកទ្វារបីនៅជាន់នេះមានប្រាង្គចំនួនប្រាំពីរធ្វើពីឥដ្ឋ រាងចតុកោណកែង ហោរណបពីរសង់ពីឥដ្ឋស្ថិតនៅជ្រុងអាគ្នេយ៍អាចជាហោត្រៃ និងអគារទ្រវែងពីរទៀតសង់ពីថ្មបាយក្រៀមនៅជ្រុងនិរតីនិងខាងលិច។ ជាន់ទីពីរមានច្រកទ្វារបីនៅខាងកើត ទីនោះមានអគាររាងកាកបាទនិងអគារតូចពីរនៅសងខាង។ នាពេលកន្លងមក អ្នកស្រាវជ្រាវបានរកឃើញសិលាចារឹក៦ផ្ទាំងនៅប្រាសាទនេះ រួមមាន K.១៩០ K.១៩១ K.១៩២ K.១៩៣ K.១៩៤ និង K.១៩៥។ សិលាចារឹក K.១៩២ ដែលលើកយកមកសិក្សានាពេលនេះ ជាសិលាចារឹកភាសាខ្មែរបុរាណ មានចំនួន២១បន្ទាត់។ ក្នុងអត្ថបទចារឹកនេះមានពាក្យថា «ម្រតាញខ្លោញវ្នំកំម្រតេងជគតគិរបុរិ» ដែលមានន័យថា ចៅអធិការប្រាសាទកម្តែងជគតសិវបុរី ឬសិវបូរ ដែលជាឈ្មោះពីបុរាណរបស់ប្រាសាទក្ដុំសណ្ដក។ ប្រាសាទនេះក៏មានឈ្មោះថាសិវបូរទន្ទេន ផងដែរតាមរយៈសិលាចារឹក K.១៩៤ K.១៩៥ និងសិលាចារឹកស្ដុកកក់ធំ K.២៥៣។

សិលាចារឹកនេះចុះកាលបរិច្ឆេទនៅមហាសករាជឆ្នាំ៨៧៨ ត្រូវនឹងគ្រិស្តសករាជ ឆ្នាំ៩៥៦ គឺស្ថិតនៅក្នុងរាជ្យព្រះបាទស្រីរាជេន្ទ្រវម៌្មទេវ។ ខ្លឹមសារនៃសិលាចារឹកនេះនិយាយពីព្រះរាជសាសន៍របស់ព្រះមហាក្សត្រ ត្រាស់បញ្ជាដល់ចៅអធិការប្រាសាទសិវបុរី/សិវបុរ(ប្រាសាទក្ដុំសណ្ដក) និងម្រតាញស្រីវីរេន្ទ្រវិជ័យ ឱ្យធ្វើបញ្ជីកត់ត្រានូវទ្រព្យទាំងឡាយរួមមានខ្ញុំបម្រើ គោ ក្របី ដំរី សេះ ស្លក ចូរៅទិ ខ្ទះ ស្រុក ស្រែ របស់ស្ដេញអញអាចារ្យកគវេន កម្ដែងអញរាជបុត្រីចាស់នៅឯផ្ទះរញ្ចោ និងកម្ដែងអញរាជបុត្រីក្មេងដែលជាប្អូន។

---

[១] អានបន្ថែម៖ https://cisark.mcfa.gov.kh/core/showsite.php?id=273

អត្ថបទដោយ៖ ហ៊ិន ឈុនតេង

សិលាចារឹកនេះក៏មានអ្នកប្រាជ្ញបានសិក្សារួចមកហើយដែរ ដូចជាលោក ស៊ក សេដេស ដែលបានសិក្សាសិលាចារឹកប្រាសាទភ្នំសណ្ដក K.១៩២ និង១៩៣ នៅក្នុងសៀវភៅសិលាចារឹកនៃប្រទេសកម្ពុជា ក្បាលទី៦ និងក្រោយមកលោក ហ្វីលីព ចេណ្ណឺរ បានសិក្សាក្នុងស្នាដៃរបស់លោក Part xml, № 42 និងចុះផ្សាយនៅគេហទំព័រ http://sealang.net/ok/corpus.htm[២]។

## ២- អត្ថបទដើមជាអក្សរទំនើប

១- ○ជយសិទ្ធិស្វាស្តិ៨៧៨គកអម្តមិកេតបុម្យចន្ទ្រវារនុមានវ្រះ

២- គាសនធូលិវ្រះបាទធូលិជេងវ្រះបាទកំម្រតេងអញតម្រតាញខ្ញោញរ្នំកំម្រ

៣- តេងជគតគិវបុរិនុម្រតាញត្រិវិរេន្ទ្រវិជយថ្វេបាញ្ជិយគិ[៣]អ្នកស្តេងអញ្ជិអាចា

៤- យ៌្យភគវននុយាកំម្រតេងអញរាជបុត្រអាយន្នុវរិនៅតអ្ន្វសនុកំម្រតេងអញតកន្សេង

៥- តផ្នូននុទ្រវ្យតមានផោងខ្ញុំថ្នុរក្រេបិតម្រ្យអ្យេះស្វោករវៅទិគទាហស្រុក

៦- ស្រេខ្ញុំវ្រះវ្នេងមនកល្បនាឃោកន្សុតឃោវរឃោភាជតៃកន្ទនតៃកន្ទិចតៃ

៧- ខ្នបកុលាកំបិតតៃមាធរតៃកន្តេងតៃលង្គាយតៃថ្ងកតៃបន្ទាសតៃកទ្រ

៨- ឃោថ្កោតឃោកញ្ញស[៤]ឃោឰតឃោកំវនក្វលបិង្គលតៃគន្ធតៃកព្រៅតៃកង្វា(ត)

៩- ឃោ(រំ)នោចក្វលសំវរឃោកំព្រៅអាត្មាប្រទានតៃកនអសតៃកនហ្សេងតៃជ្វិកតៃកំប្រូត

១០- តៃសំអបតៃកញ្ជោតៃឧត្បលក្វលចំលាកតៃសំអបក្វនសំអបផោងតៃកំបិតនុក្វន

១១- កំបិតផោងតៃកញ្ជានតៃកំបិតនុក្វនកំបិតផោងតៃបិន្ទាតៃថ្បលគិផ្ទះហក្វនបិន្ទា

---

[២] សូមជ្រើសយកលេខ «K.192»។

[៣] លើសំណៅផ្តិតឃើញជា «គិ» ដែលទំនងជាអ្នកចារច្រឡំ។

[៤] លោក សេដេស និងលោក ចេណ្ណឺរ អានជា «កញុស» ប៉ុន្តែយើងអានជា «កញ្ញស» ដោយសារតួអក្សរ «ញ្ញ» មានរូបរាងដូចគ្នានឹងពាក្យ «កញ្ញាន» នៅត្រង់បន្ទាត់ទី១១ ក្នុងសិលាចារឹកនេះ។ ម្យ៉ាងទៀត យើងប្រទះឃើញពាក្យ «កញ្ញស» ដែលជាឈ្មោះរបស់អ្នកបម្រើភេទស្រីនិងប្រុសនៅក្នុងសិលាចារឹកនានាដូចជា K.៩៩ K.៣១២ K.៣១៨ និងK.៦៦៩(២ដង)។

អត្ថបទដោយៈ ហ៊ុន ឈុនតេង

១២- នុតែកនឥនតែបន្ទំ្ហយោកនរាកយោវម្ម៌គិវយោកំព្រៀយោគន្ធយោបន្ទសយោ

១៣- សំម្ហតយោកន្សោ្រយោថ្ងំយោកំវាសតែជម្ម៌សិបន្ទំ្ហផអ្វនបន្ទំ្ហវ្យរតែក្រតែឧត្ប

១៤- លសោតយោកំបុរតែបន្ទាសក្វនបន្ទាសផោងតែសំអបតែបន្ទ្មាននុក្វនបន្ទ្មាន

១៥- ប្រៃតាញ្ញតឹតែបន្ទ្មានយោមាហេន្ទ្រតែកញ្ចុនុក្វនកញ្ចុផោងអ្មេបន្ទាសនុបន្ទាស

១៦- ទយវាបគបនុគណាវាបផោងតែស្រាច្តវ្រះនុក្វនផោងតែកំបិតសោតនុក្វន

១៧- ផោងតែឆ្កេតែកំបុរនុ[[ក្វន]]កំបុរផោងស្រេអំរិជេងវ្រះទំនប្បចបត្រវាងស្វាយ

ទៅល្វះ

១៨- ស្តុកក្របិល្វះឦគានបទនុស្រុកផ្វេគិស្រុកបាសខ្មៅនុស្រេផ្វេគិស្រេអំវេវាបគិខា

១៩- គាន្តិអាយវ្រៃបតោនុធ្បារផ្វេគិស្រេបាសខ្យលស្រេវកទ្បាំនុធ្បារផ្វេគិស្រេចំនាំ

២០- ស្តេងអញ្ញអាយវ្យោមស្រេចំនាំស្តេងអញ្ញអាយស្តុករន្សិជ្ទះចន្ទ្វវ្រច្ចនេះ

២១- តអំបាល្វគិ[[យ]]ជមានតល៎

## ៣- អត្ថបទប្រែសម្រួល

(១-៦) ជ័យ សិទ្ធិ សួស្តី មហាសករាជឆ្នាំ៨៧៨ ទី៨កើត ខែបុស្ស ថ្ងៃចន្ទ នូវមានព្រះរាជសាសន៍នៃធូលីព្រះបាទធូលីជើងព្រះកម្តែងអញ (ត្រាស់)ដល់ម្រតាញអធិការប្រាសាទសិវបូរ និងម្រតាញស្រីវីរេន្ទ្រាវិជ័យ (ឱ្យ)ធ្វើបញ្ជី(របស់)ស្តេញអញអាចារ្យកគវន យាយកម្តែងអញរាជបុត្រីដ៏ចាស់នៅឯផ្លូវញ្ញោ កម្តែងអញរាជបុត្រីដ៏ក្មេងដែលជាប្អូន និងទ្រព្យផងទាំងឡាយមានដូចជាខ្ញុំបម្រើ គោ ក្របី ដំរី សេះ ស្លក ចូរៅទិ ខ្ទះ ស្រុក ស្រែ។

(៦-១៧) ខ្ញុំបម្រើព្រះភ្លើងដែលរៀបចំមានយោកន្សេត យោវរ យោភាជ តែកន្ទួន តែកន្និច តែខ្ចបនិងបងប្អូនស្រី(គឺ)កំបិត តែមាធវី តែកន្តេង តែលង្កាយ តែឞ្ចក តែបន្ទាស តែភទ្រ យោថ្កោត យោកញ្ញ្សេ យោពុត យោកំវននិងបងប្អូនប្រុស(គឺ)បិង្គល តែគន្ធ តែកព្រៀ តែកង្វា(ត) យោ(រំ)នោចនិងបងប្អូនប្រុស(គឺ)សំវរ យោកំព្រៀអាត្មាប្រទាន តែកនអស តែកនហ្សង តែដ្វិក តែកំប្រួត តែសំអប់ តែកញ្ជា តែឧត្បលនិងបងប្អូនប្រុស(គឺ)ចំលាក តែសំអបនិងកូនតែសំអបផង តែកំបិតនិងកូនតែកំបិតផង តែកញ្ចាន តែកំបិតនិងកូនតែ

អត្ថបទដោយ៖ ហ៊ុន ឈុនតេង

កំបិតផង តៃបិន្ទា តៃប្បុលនិងកូនឈ្មោះបិន្ទា តៃកនតន និងតៃបន្ទើម យោកទ្រាក យោវម្ម៑ សិវ យោកំវៀ យោគន្ធ យោបន្ទស យោសំម្វុត យោកន្សៅ យោថ្ងើម យោកំវាស តៃធម្ម៑ សិបន្ទើមនិងប្អូនបន្ទើមពីរនាក់ តៃក្រ តៃឧត្បលម្នាក់ទៀតសោត យោកំបុរ តៃបន្ទាសនិងកូនបន្ទាសផង តៃសំអប តៃបន្ទានិងកូនបន្ទានព្រៃទទឹម តៃបន្ទាន យោមាហេន្ទ្រ តៃកញ្ចុ និងកូនកញ្ចុផង ម្តាយបន្ទាសនិងបន្ទាសម្នាក់ទៀត វាបគបនិងគ្នីគ្នាវាបផង តៃស្រាច្តវ្រះ និងកូនផង តៃកំបិតម្នាក់ទៀតសោតនិងកូនផង តៃឆ្កេ តៃកំបុរនិងកូនកំបុរផង។

(១៧-២០) ស្រែចាប់ពីជើងព្រះទំនប់ចាប់ពីត្រពាំងស្វាយទៅដល់ស្តុកក្របី ទៅដល់ព្លៀសានបទ។ នូវស្រុកផល គឺស្រុកបាសខ្មៅ នូវស្រែផល គឺស្រែដែលធ្វើដោយវាបសិខាសាន្តិនៅឯព្រៃផ្តៅ នូវច្បារផល គឺស្រែបាសខ្យល់ ស្រែវកទ្នឹម នូវច្បារផល គឺស្រែដែលជាគ្រឿងរណ្តាប់បូជាស្តែងអញនៅឯវ្យោម។ ស្រែដែលជាគ្រឿងរណ្តាប់បូជាស្តែងអញនៅឯស្តុកឫស្សីឈ្មោះចង្វូរព្រេច។

(២០-២១) ទាំងអម្បាលនេះគឺម្ចាស់ទាន(ថ្វាយ)ដល់[ប្រាសាទ]។

## ៤- វាក្យសព្ទសំខាន់ៗ

| | |
|---|---|
| ថ្វើ | ធ្វើ (ថ > ធ, េ◌ > េ◌ី)។ |
| បាញ្ចិយ | (សំ.) បញ្ជី។ |
| យា | យាយ។ |
| អ្វស | ចាស់។ |
| កន្សៀង | ក្មេង (◌្យ > េ◌)។ |
| ផ្អូន | ប្អូន (◌្វ > ◌ូ)។ |
| ថ្មុរ | គោ។ |
| តម្រ្យ | ដំរី (ត > ដ, ◌្យ > ◌ី)។ |
| អេ្សះ | សេះ។ |
| វ្វេង | ភ្លើង (វ > ព > ភ, េ◌>េ◌ី)។ វ្រះវ្វេង = ព្រះភ្លើង, ព្រះអគ្គី។ |

អត្ថបទដោយ៖ ហ៊ុន ឈុនតេង

**កល្បនា** គ្រឿងវណ្ណាប់បូជា។

**ក្វន** កូន (◌្វ>◌ូ)។

**កុលា** បងប្អូនស្រី។

**ក្វល** **បងប្អូនប្រុស។**

**ទយ~ទៃ** ដទៃ, ផ្សេង, ផ្សេងទៀត។

**គណា** (សំ. គណ) > គ្នា = ក្រុម, ពួក, គ្នីគ្នា។

**ចប** ចាប់។

**ផ្វេ** **(សំ.)** ផ្វៃ (េ◌ > ៃ◌) ផ្លែ, ផ្លែផ្កា, កោគផល។

**អំពេ** អំពើ (េ◌>ៃ◌) អំពី, អ្វីដែលបានធ្វើហើយ។

**យជមាន** (សំ.) មនុស្សធម្មតាឬព្រាហ្មណ៍ដែលថ្វាយឬរៀបចំតង្វាយបូជាព្រះឬអាចហៅជាខ្ញីថាម្ចាស់ទាន។

## ឯកសារពិគ្រោះ


CISARK

Phnom Sandak. https://cisark.mcfa.gov.kh/core/showsite.php?id=273

Cœdès, G.

1954. Inscriptions du Phnoṃ Sandak(K.192, 193), Stèle de Rājendravarman (K.192) in *Inscriptions du Cambodge*, Vol. 6. Paris.

Jenner, P.

Stele of Rājendravarman in *Part xml, № 42*. http://sealang.net/ok/corpus.htm


អត្ថបទដោយៈ ហ៊ុន ឈុនតេង

## បញ្ជីរូបភាព



ទិដ្ឋភាពប្រាសាទភ្នំសណ្ដក (ប្រភពរូប៖ ស៊ឹម នីឡា)



ទិដ្ឋភាពប្រាសាទភ្នំសណ្ដក (ប្រភពរូប៖ ស៊ឹម នីឡា)

អត្ថបទដោយ៖ ហ៊ុន ឈុនតេង



ទិដ្ឋភាពប្រាសាទភ្នំសណ្ដក (ប្រភពរូបៈ ស៊ឹម នីឡា)



ទិដ្ឋភាពកំពែងថ្មបាយក្រៀមប្រាសាទភ្នំសណ្ដក (ប្រភពរូបៈ ស៊ឹម នីឡា)

អត្ថបទដោយៈ ហ៊ុន ឈុនតេង



n. 762 / K. 192

សំណៅផ្តិតសិលាចារឹកប្រាសាទភ្នំសណ្តក K.១៩២ (ប្រភពរូបៈ EFEO តាមរយៈ CISARK)

អត្ថបទដោយៈ ហ៊ិន ឈុនតេង